# សុន្ទរកថារបស់លោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ
## ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
## សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន
## ១៣ កុម្ភៈ ២០១៣

សូមគោរព លោក ថោង សារុណ នាយកប្រតិបត្តិអង្គការអប់រំវិជ្ជាជីវដើម្បីកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍សង្គម!
សូមគោរព អស់លោក លោកស្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការចូលរួមពិធីចុះហត្ថលេខា លើការផ្តល់ជំនួយ សម្រាប់គម្រោងសាងសង់អគារសាលាបឋមសិក្សាលោប ជាមួយតំណាងអង្គការអប់រំវិជ្ជាជីវដើម្បីកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សង្គម(VAPSD)។ ខ្ញុំក៏មានក្តីរីករាយយ៉ាងខ្លាំងទៀតផងដែរ ដែលពិធីចុះហត្ថលេខានេះត្រូវបានធ្វើឡើងក្នុងឱកាសពិសេសនាឆ្នាំ២០១៣នេះ ដែលជាឆ្នាំគម្រប់ខួបលើកទី៦០នៃមិត្តភាពរវាងប្រទេសកម្ពុជា និងជប៉ុន។

គម្រោងនេះមានគោលបំនងធ្វើឲ្យប្រសើរឡើងនូវបរិដ្ឋានអប់រំមួយនៅក្នុងសាលាបឋមសិក្សាលោប តាមរយៈការសាងសង់អគារសិក្សាមួយខ្នងមាន៥បន្ទប់ ព្រមទាំងសម្ភារៈបរិក្ខានិងបំពាក់នូវអាងស្តុកទឹក។ ថវិការជំនួយដែលនឹងត្រូវផ្តល់ជូនសម្រាប់គម្រោងនេះគិតជាទឹកប្រាក់គឺ៧៧.២៨៣ដុល្លារអាមេរិក។ ក្នុងចំណោមអគារសិក្សាពីរខ្នងដែលមាននៅក្នុងសាលានោះ អាគារឈើដែលត្រូវបានសាងសង់តាំងពីឆ្នាំ១៩៩៣ មានសភាពចាស់ទ្រុឌទ្រោមដល់កម្រិតអាចនឹងមានគ្រោះថ្នាក់សម្រាប់ការសិក្សា។ តាមរយៈការកែលម្អសម្ភារៈបរិក្ខារបស់សាលាបឋមសិក្សានេះ យើងរំពឹងថាគម្រោងនេះថា នឹងផ្តល់ជាប្រយោជន៍ដល់ក្មួយៗសិស្សានុសិស្សប្រមាណ៥០០នាក់ដែលកំពុងសិក្សា ហើយនឹងផ្តល់ផលប្រយោជន៍សម្រាប់ក្មួយៗសិស្សានុសិស្សដែលនឹងមកចុះឈ្មោះចូលរៀននាជំនាន់ក្រោយៗទៀតផងដែរ។

ការអប់រំ និងការអភិវឌ្ឍធនធានមនុស្សជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍប្រទេសកម្ពុជានាពេលអនាគត។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ទៅលើវិស័យទាំងនេះដោយចាត់ទុកជាមុំមួយក្នុងចំណោមមុំទាំងបួននៃយុទ្ធសាស្ត្រចតុកោណសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។ រាជរដ្ឋាភិបាលកម្ពុជាក៏កំពុងខិតខំប្រឹងប្រែង បង្កើននូវចំនួនសាលាបឋមសិក្សាដើម្បីសម្រេចឲ្យបាននូវការផ្សព្វផ្សាយយ៉ាងពេញលេញមួយសម្រាប់ការអប់រំថ្នាក់បឋមត្រឹមឆ្នាំ២០១៥។

ដោយយល់អំពីសារៈសំខាន់នៃវិស័យអប់រំសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅក្នុងប្រទេសកម្ពុជា រដ្ឋាភិបាលប្រទេសជប៉ុនបាននិងកំពុងជួយដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈជំនួយទាំង សម្ភារៈ និងបច្ចេកទេស។ គម្រោងថ្មីមួយនេះ ស្របជាមួយនឹងគោលការគ្រឹះរបស់ប្រទេសជប៉ុនសម្រាប់ប្រទេសកម្ពុជា និងស្របទៅនឹងគោលការណ៍គម្រោងជំនួយដែលបានបង្កើតឡើងដើម្បីលើកកម្ពស់សុវត្ថិភាពប្រជាជនដែលងាយរងគ្រោះផងដែរ។

ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានាថ្ងៃនេះ នឹងត្រូវបានអនុវត្តយ៉ាងរលូន និងមានប្រសិទ្ធភាពដោយដៃគូរបស់យើង គឺអង្គការអប់រំវិជ្ជាជីវដើម្បីកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សង្គម ព្រមទាំងត្រូវបានថែទាំយ៉ាងល្អដើម្បីឲ្យសិស្សានុសិស្សយ៉ាងច្រើនបានទទួលផលប្រយោជន៍ពីគម្រោងនេះ។

ជាចុងក្រោយ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!